# ទ្រឹស្តីទូទៅស្តីពី
# អង្គហេតុចំបងដែលជាធាតុផ្សំ

វិទ្យាស្ថានស្រាវជ្រាវច្បាប់ទូទៅ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
សាស្ត្រាចារ្យ Kai Yuji

# អ្វីទៅ អង្គហេតុចំបងដែលជាធាតុផ្សំ ?

- ច្បាប់សារធាតុ : ក្រមរដ្ឋប្បវេណី ជាដើម
  - មានចែងថា បើសិនជាមានអង្គហេតុពិសេសណាមួយ អានុភាពគតិយុត្តិនឹងកើតមានឡើង ដូចជា កំណើត ឬការរលត់នៃសិទ្ធិ ជាអាទ៏។
- អង្គហេតុចំបងដែលជាធាតុផ្សំ :
  - អង្គហេតុចាំបាច់ដើម្បីបង្កើតអានុភាពគតិយុត្តិ
  - ពេលជំនុំជម្រះ ត្រូវគិតជាប្រចាំថា អ្វីទៅអង្គហេតុចំបងដែលជាធាតុផ្សំ។
  - ត្រូវគិតថា តើភាគីណាមានការទទួលខុសត្រូវក្នុងការអះអាង និងបញ្ជាក់ភស្តុតាងអំពីអង្គហេតុចំបងដែលជាធាតុផ្សំនោះ ដើម្បីរៀបចំចំណុចវិវាទ។

# ឧទាហរណ៍

- ការអះអាងរបស់ដើមចោទ
  - នៅថ្ងៃទី1 ខែមីនា ឆ្នាំ2013 ខ្ញុំនិងចុងចម្លើយបានព្រមព្រៀងអំពីកិច្ចសន្យាឱ្យចុងចម្លើយខ្ចីប្រាក់១ម៉ឺនដុល្លារ ដោយឱ្យសងនៅមួយឆ្នាំក្រោយ គឺថ្ងៃទី1 ខែមីនា ឆ្នាំ2014 ហើយបានប្រគល់ប្រាក់១ម៉ឺនដុល្លារតាមកិច្ចសន្យានោះទៅឱ្យចុងចម្លើយ។
  - ក៏ប៉ុន្តែ ទោះជាកាលកំណត់សងបានកន្លងផុតហើយក៏ដោយ ចុងចម្លើយចេះតែនិយាយថា "សូមចាំបន្តិច!" ហើយមិនព្រមសងទាល់តែសោះ។ ដូច្នេះ ខ្ញុំសូមទាមទារឱ្យចុងចម្លើយសង១ម៉ឺនដុល្លារនោះ។

# ឧទាហរណ៍

- ការអះអាងរបស់ចុងចម្លើយ
  - ខ្ញុំទទួលស្គាល់ថា នៅថ្ងៃទី1 ខែមីនា ឆ្នាំ2013 ខ្ញុំពិតជាបានទទួលប្រាក់១ម៉ឺនដុល្លារពីដើមចោទពិតមែន។ ក៏ប៉ុន្តែ ប្រាក់នេះ គឺដើមចោទបានចងដៃខ្ញុំ ពេលខ្ញុំការ ដូច្នេះមិនចាំបាច់សងទេ។
  - ខ្ញុំមិនដែលនិយាយប្រាប់ដើមចោទថា “សូមចាំបន្តិច” ម្តងណាទេ។

# ឧទាហរណ៍

<ចូរពិចារណាពីចៅក្រម និង មេធាវី>

- នៅក្នុងការជំនុំជម្រះនេះ តើចំណុចវិវាទមាននៅត្រង់ណា?
- តើចំណុចវិវាទគឺ “តើគឺជាប្រាក់កម្ចី ឬក៏ជាប្រាក់ប្រទានកម្ម?” មែនឬទេ ?
- បញ្ហាចុងចម្លើយនិយាយថា “សូមចាំបន្តិច” គឺជាចំណុចវិវាទដែរឬទេ ?
- ក្នុងករណីដែលមិនមានភស្តុតាងគ្រប់គ្រាន់ ហើយមិនដឹងច្បាស់ថា ជាប្រាក់កម្ចី ឬប្រទានកម្មទេ ត្រូវធ្វើដូចម្តេចដែរ ?

# ឧទាហរណ៍

<សូមរៀបចំមើលឡើងវិញ>

1. គោលគំនិតនៃការទាមទារ គឺ?
2. កម្មវត្ថុនៃបណ្ដឹង គឺ?
3. មូលហេតុនៃការទាមទារ គឺ?
4. អត្ថន័យតាមផ្លូវច្បាប់នៃការអះអាងរបស់ចុងចម្លើយ គឺ?
5. ចំណុចវិវាទគឺ?

# 1. គោលគំនិតនៃការទាមទារ

- ការទាមទាររបស់ដើមចោទ ត្រូវបានបង្ហាញយ៉ាងងាយស្រួលធម្មតា នៅក្នុងគោលគំនិតនៃការទាមទារ។
- ក្នុងករណីដែលដើមចោទឈ្នះពេញលេញ គោលគំនិតនៃការទាមទារនេះនឹងសរសេរដូចគ្នានៅក្នុងសេចក្តីសម្រេចបញ្ចប់។
- គោលគំនិតនៃការទាមទារក្នុងរឿងក្តីនេះគឺ
  - “ចុងចម្លើយត្រូវបង់ប្រាក់១ម៉ឺនដុល្លារចំពោះដើមចោទ”។

# ឧទាហរណ៍

<សូមរៀបចំមើលឡើងវិញ>

1. គោលគំនិតនៃការទាមទារ គឺ?
2. កម្មវត្ថុនៃបណ្ដឹង គឺ?
3. មូលហេតុនៃការទាមទារ គឺ?
4. អត្ថន័យតាមផ្លូវច្បាប់នៃការអះអាងរបស់ចុងចម្លើយ គឺ?
5. ចំណុចវិវាទគឺ?

# 2. កម្មវត្ថុនៃបណ្តឹង

អ្វីទៅ កម្មវត្ថុនៃបណ្តឹង?

- សិទ្ធិដែលជាមូលដ្ឋាននៃការទាមទាររបស់ដើមចោទ
- កម្មវត្ថុនៃការជំនុំជម្រះ
- ដើមចោទជាអ្នកកំណត់នូវកម្មវត្ថុនេះ
- កម្មវត្ថុនេះចងតុលាការ

ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា182 (ចំណុចដែលត្រូវធ្វើការវិនិច្ឆ័យដោយសាលក្រម)

1. តុលាការត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់ដែលភាគីបានសុំ ។
2. តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ ។

# 2. កម្មវត្ថុនៃបណ្ដឹង

- ដើមចោទបានអះអាងថា នេះគឺជាប្រាក់កម្ចី ដូច្នេះសូមសង។
- ការទាមទាររបស់ដើមចោទ គឺ ?
- មូលដ្ឋានតាមផ្លូវច្បាប់ គឺ ?

ក្រមរដ្ឋប្បវេណី មាត្រា578 (និយមន័យនៃការខ្ចីបរិភោគ)

ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ស្បៀងអាហារ ស្រូវ ឬ វត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ ។

ក្រមរដ្ឋប្បវេណី មាត្រា591 (ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់របស់អ្នកខ្ចី)

(1) អ្នកខ្ចី មានករណីយកិច្ចត្រូវសងទៅអ្នកឱ្យខ្ចី នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង ។

# 2. កម្មវត្ថុនៃបណ្តឹង

- ការទាមទាររបស់ដើមចោទ គឺ ?
  - ទាមទារឱ្យសងប្រាក់កម្ចី

- មូលដ្ឋានតាមផ្លូវច្បាប់ គឺ ?
  - កិច្ចសន្យាខ្ចីបរិភោគ

# 2. កម្មវត្ថុនៃបណ្តឹង

- កម្មវត្ថុនៃបណ្តឹង ៖
  - សិទ្ធិទាមទារឱ្យសងប្រាក់កម្ចី ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ

# ឧទាហរណ៍

<សូមរៀបចំមើលឡើងវិញ>

1. គោលគំនិតនៃការទាមទារ គឺ?
2. កម្មវត្ថុនៃបណ្ដឹង គឺ?
3. មូលហេតុនៃការទាមទារ គឺ?
4. អត្ថន័យតាមផ្លូវច្បាប់នៃការអះអាងរបស់ចុងចម្លើយ គឺ?
5. ចំណុចវិវាទគឺ?

# 3. មូលហេតុនៃការទាមទារ

មូលហេតុនៃការទាមទារ គឺជា ?

- អង្គហេតុដែលចាំបាច់យ៉ាងតិចបំផុត ដើម្បីបង្កើតសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង (អង្គហេតុចំបង)
- ត្រូវពិចារណាមើលមាត្រាដែលជាមូលដ្ឋាននៃកំណើតសិទ្ធិ។

ក្រមរដ្ឋប្បវេណី មាត្រា578 (និយមន័យនៃការខ្ចីបរិភោគ)

ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ស្បៀងអាហារ ស្រូវ ឬ វត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ ។

ក្រមរដ្ឋប្បវេណី មាត្រា591 (ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់របស់អ្នកខ្ចី)

(1) អ្នកខ្ចី មានករណីយកិច្ចត្រូវសងទៅអ្នកឱ្យខ្ចី នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង ។

# 3. មូលហេតុនៃការទាមទារ

ដើម្បីបង្កើតសិទ្ធិនេះ ត្រូវមាន

A) ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ (មាត្រា578)

B) ការប្រគល់ប្រាក់ដោយផ្អែកលើកិច្ចសន្យា (មាត្រា591)

C) កាលកំណត់សងបានមកដល់ (មាត្រា591)

ក្រមរដ្ឋប្បវេណី មាត្រា578 (និយមន័យនៃការខ្ចីបរិភោគ)

ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ស្បៀងអាហារ ស្រូវ ឬ វត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ ។

ក្រមរដ្ឋប្បវេណី មាត្រា591 (ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់របស់អ្នកខ្ចី)

(1) អ្នកខ្ចី មានករណីយកិច្ចត្រូវសងទៅអ្នកឱ្យខ្ចី នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង ។

# 3. មូលហេតុនៃការទាមទារ

ដើម្បីបង្កើតសិទ្ធិនេះ ត្រូវមាន

A) ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ (មាត្រា578)

- អ្នកឱ្យខ្ចី→អ្នកខ្ចី បានសន្យាប្រគល់និងទទួលប្រាក់
- អ្នកខ្ចី→អ្នកឱ្យខ្ចី បានសន្យាសង
- បានព្រមព្រៀងអំពីកាលកំណត់សង

B) ការប្រគល់ប្រាក់ដោយផ្អែកលើកិច្ចសន្យា (មាត្រា591)

- បានប្រគល់ប្រាក់
- ដោយផ្អែកលើកិច្ចសន្យា

C) កាលកំណត់សងបានមកដល់ (មាត្រា591)

ក្រមរដ្ឋប្បវេណី មាត្រា578 (និយមន័យនៃការខ្ចីបរិភោគ)

ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ស្បៀងអាហារ ស្រូវ ឬ វត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ ។

# 3. មូលហេតុនៃការទាមទារ

មូលហេតុនៃការទាមទារ :

A) ដើមចោទនិងចុងចម្លើយបានង្កើតកិច្ចសន្យាខ្ចីបរិភោគ
   - ➢ មានការព្រមព្រៀងអំពីទឹកប្រាក់កម្ចី និង កាលកំណត់សង

B) បានប្រគល់ប្រាក់

C) ចំណុច B គឺផ្អែកលើកិច្ចសន្យានៃចំណុច A

D) កាលកំណត់សងបានមកដល់

※ទាល់តែស្របនឹងល័ក្ខខ័ណ្ឌទាំងអស់នេះ ទើបសិទ្ធិនេះកើតមានឡើង។ បើសិនជាខ្វះល័ក្ខខ័ណ្ឌណាមួយក៏ដោយ ក៏ត្រូវច្រានចោលនូវការទាមទារដែរ។

※ដើមចោទត្រូវធ្វើការអះអាងទាំងអស់នេះ។

→ការទទួលខុសត្រូវក្នុងការអះអាង

※បើសិនជាមានវិវាទ ដើមចោទត្រូវធ្វើការបញ្ជាក់ភស្តុតាង។

→ការទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង

# 3. មូលហេតុនៃការទាមទារ

មូលហេតុនៃការទាមទារ :

A) "នៅថ្ងៃទី1 ខែមីនា ឆ្នាំ2013 ដើមចោទនិងចុងចម្លើយបានព្រមព្រៀងអំពីកិច្ចសន្យាឱ្យចុងចម្លើយខ្ចីប្រាក់១ម៉ឺនដុល្លារ ដោយឱ្យសងនៅមួយឆ្នាំក្រោយ គឺថ្ងៃទី1 ខែមីនា ឆ្នាំ2014 ។"

B) "ដើមចោទបានប្រគល់ប្រាក់១ម៉ឺនដុល្លារ នៅថ្ងៃទី1 ខែមីនា ឆ្នាំ2013 ទៅឱ្យចុងចម្លើយ។"

C) "ការប្រគល់ប្រាក់នៃB ត្រូវបានធ្វើឡើងដោយផ្អែកលើកិច្ចសន្យានៃA។"

D) "ថ្ងៃទី1 ខែមីនា ឆ្នាំ2014 បានមកដល់។"

# ឧទាហរណ៍

<សូមរៀបចំមើលឡើងវិញ>

1. គោលគំនិតនៃការទាមទារ គឺ?
2. កម្មវត្ថុនៃបណ្តឹង គឺ?
3. មូលហេតុនៃការទាមទារ គឺ?
4. អត្ថន័យតាមផ្លូវច្បាប់នៃការអះអាងរបស់ចុងចម្លើយ គឺ?
5. ចំណុចវិវាទគឺ?

# 4. ការអះអាងរបស់ចុងចម្លើយ

- ការអះអាងរបស់ចុងចម្លើយ
  - ខ្ញុំទទួលស្គាល់ថា នៅថ្ងៃទី1 ខែមីនា ឆ្នាំ2013 ខ្ញុំពិតជាបានទទួលប្រាក់១ម៉ឺនដុល្លារពីដើមចោទពិតមែន។ ក៏ប៉ុន្តែ ប្រាក់នេះ គឺដើមចោទបានចងដៃខ្ញុំ ពេលខ្ញុំការ ដូច្នេះមិនចាំបាច់សងទេ។

- ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ចុងចម្លើយ ចំពោះមូលហេតុនៃការទាមទារ គឺ ?

# 4. ការអះអាងរបស់ចុងចម្លើយ

- ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ

A) ដើមចោទនិងចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីបរិភោគ
→មិនទទួលស្គាល់

B) ការប្រគល់ប្រាក់
→ទទួលស្គាល់

C) ការប្រគល់ប្រាក់នៃB គឺបានធ្វើឡើងដោយផ្អែកលើកិច្ចសន្យានៃA
→មិនទទួលស្គាល់

D) កាលកំណត់សងបានមកដល់
→អង្គហេតុជាក់ស្តែង

※AនិងC គឺជាចំណុចវិវាទ។ BនិងD មិនមែនជាចំណុចវិវាទទេ។

# ឧទាហរណ៍

<សូមរៀបចំមើលឡើងវិញ>

1. គោលគំនិតនៃការទាមទារ គឺ?
2. កម្មវត្ថុនៃបណ្តឹង គឺ?
3. មូលហេតុនៃការទាមទារ គឺ?
4. អត្ថន័យតាមផ្លូវច្បាប់នៃការអះអាងរបស់ចុងចម្លើយ គឺ?
5. ចំណុចវិវាទគឺ?

# 5. ចំណុចវិវាទ

A) តើបាន ឬមិនបានបង្កើតកិច្ចសន្យាខ្ចីបរិភោគ?

C) តើការប្រគល់ប្រាក់១ម៉ឺនដុល្លារ គឺជាការប្រគល់ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែរឬទេ ?

- ចំពោះចំណុចវិវាទខាងលើនេះ ដើមចោទជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង។
- ចំពោះចំណុចវិវាទទាំងនេះ តុលាការត្រូវធ្វើការវិនិច្ឆ័យដោយផ្អែកលើភស្តុតាង។

# 5. ចំណុចវិវាទ

A) តើបាន ឬមិនបានបង្កើតកិច្ចសន្យាខ្ចីបរិភោគ?
C) តើការប្រគល់ប្រាក់១ម៉ឺនដុល្លារ គឺជាការប្រគល់ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែរឬទេ ?

- តើចុងចម្លើយបាននិយាយថា “សូមចាំបន្តិច” ដែរឬទេ ?
  - ➢ បើសិនជាអង្គហេតុនេះមានពិតមែន អាចសន្និដ្ឋានថា កិច្ចសន្យានេះត្រូវបានបង្កើតពិតមែន។

អង្គហេតុប្រយោល (“សូមចាំបន្តិច”)

↓

អង្គហេតុចំបង (អង្គហេតុនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគ)

# 5. ចំណុចវិវាទ

A) តើបាន ឬមិនបានបង្កើតកិច្ចសន្យាខ្ចីបរិភោគ?
C) តើការប្រគល់ប្រាក់១ម៉ឺនដុល្លារ គឺជាការប្រគល់ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែរឬទេ ?

- ការអះអាងរបស់ចុងចម្លើយដែលថា "ជាប្រទានកម្ម" គឺជាអ្វី ?
  - នេះគឺគ្រាន់តែជាមូលហេតុនៃការប្រគល់ប្រាក់មិនមែនផ្អែកលើកិច្ចសន្យាខ្ចីបរិភោគប៉ុណ្ណោះ។
  - មិនទទួលស្គាល់នូវមូលហេតុនៃចំណុចវិវាទC
  - មិនចាំបាច់ធ្វើការវិនិច្ឆ័យថា តើជាមានប្រទានកម្ម ឬទេ នោះទេ។

# 5. ចំណុចវិវាទ

A) តើបាន ឬមិនបានបង្កើតកិច្ចសន្យាខ្ចីបរិភោគ?

C) តើការប្រគល់ប្រាក់១ម៉ឺនដុល្លារ គឺជាការប្រគល់ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែរឬទេ ?

- បើសិនជាមិនដឹងថា តើនេះគឺជាការឱ្យខ្ចី ឬជាប្រទានកម្ម តាមភស្តុតាងទេ ត្រូវធ្វើម្តេច ?
  - ដើមចោទ មានការទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាងស្តីពីការឱ្យខ្ចី។
  - មូលហេតុនៃការទាមទារ A និង C មិនអាចបញ្ជាក់ដោយភស្តុតាងបាន ដូច្នេះ ត្រូវច្រានចោលនូវការទាមទារ។

# ប្តូរដំបូងក្រោម

មូលហេតុនៃការទាមទារ

| | | |
|---|---|---|
| A | X・Y បានព្រមព្រៀងនៅ 2013.3.1 អំពីកិច្ចសន្យាឱ្យចងចម្លើយខ្ចីប្រាក់១ម៉ឺនដុល្លារ ដោយឱ្យសងនៅ 2014.3.1 | × |
| B | X→Y 2013.3.1 បានប្រគល់១ម៉ឺនដុល្លារ | ○ |
| C | ការប្រគល់ប្រាក់នៃ B ធ្វើឡើងដោយផ្អែកលើកិច្ចសន្យានៃ A | × |
| D | 2014.3.1 បានមកដល់ | ជាក់ស្តែង |

# ឧទាហរណ៍ II

- ការអះអាងរបស់ដើមចោទ
  - នៅថ្ងៃទី1 ខែមីនា ឆ្នាំ2013 ខ្ញុំបានឱ្យចុងចម្លើយខ្ចីប្រាក់១ម៉ឺនដុល្លារ ដោយកំណត់ឱ្យសងនៅថ្ងៃទី 1 ខែមីនា ឆ្នាំ2014។ ក៏ប៉ុន្តែ គាត់មិនសងទាល់តែសោះ ហេតុនេះហើយ ខ្ញុំទាមទារឱ្យចុងចម្លើយសងប្រាក់១ម៉ឺនដុល្លារនោះ។
- ការអះអាងរបស់ចុងចម្លើយ
  - ខ្ញុំពិតជាបានខ្ចីប្រាក់១ម៉ឺនដុល្លារពីដើមចោទមែន តែនៅថ្ងៃទី1 ខែមីនា ឆ្នាំ2014 ខ្ញុំបានសងរួចរាល់ហើយ។

# ឧទាហរណ៍ II

## <សូមរៀបចំមើលឡើងវិញ>

1. គោលគំនិតនៃការទាមទារ គឺ?
2. កម្មវត្ថុនៃបណ្តឹង គឺ?
3. មូលហេតុនៃការទាមទារ គឺ?
4. អត្ថន័យតាមផ្លូវច្បាប់នៃការអះអាងរបស់ចុងចម្លើយ គឺ?
5. ចំណុចវិវាទគឺ?

# 1. គោលគំនិតនៃការទាមទារ

- “ចុងចម្លើយត្រូវបង់ប្រាក់១ម៉ឺនដុល្លារចំពោះដើមចោទ”

# 2. កម្មវត្ថុនៃបណ្តឹង

- សិទ្ធិទាមទារឱ្យសងប្រាក់កម្ចីដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ

# 3. មូលហេតុនៃការទាមទារ

A) ដើមចោទនិងចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីបរិភោគ
B) ការប្រគល់ប្រាក់
C) Bត្រូវបានធ្វើឡើងដោយផ្អែកលើកិច្ចសន្យានៃA
D) កាលកំណត់សងបានមកដល់

# 3. មូលហេតុនៃការទាមទារ

មូលហេតុនៃការទាមទារ :

A) “នៅថ្ងៃទី1 ខែមីនា ឆ្នាំ2013 ដើមចោទនិងចុងចម្លើយបានព្រមព្រៀងអំពីកិច្ចសន្យាឱ្យចុងចម្លើយខ្ចីប្រាក់១ម៉ឺនដុល្លារ ដោយឱ្យសងនៅមួយឆ្នាំក្រោយ គឺថ្ងៃទី1 ខែមីនា ឆ្នាំ2014 ។”

B) “ដើមចោទបានប្រគល់ប្រាក់១ម៉ឺនដុល្លារ នៅថ្ងៃទី1 ខែមីនា ឆ្នាំ2013 ទៅឱ្យចុងចម្លើយ។”

C) “ការប្រគល់ប្រាក់នៃB ត្រូវបានធ្វើឡើងដោយផ្អែកលើកិច្ចសន្យានៃA។”

D) “ថ្ងៃទី1 ខែមីនា ឆ្នាំ2014 បានមកដល់។”

# 4. ការអះអាងរបស់ចុងចម្លើយ

- ការអះអាងរបស់ចុងចម្លើយ

  ខ្ញុំពិតជាបានខ្ចីប្រាក់១ម៉ឺនដុល្លារពីដើមចោទមែន តែនៅថ្ងៃទី1 ខែមីនា ឆ្នាំ2014 ខ្ញុំបានសងរួចរាល់ហើយ។

- មាត្រា 384 (ករណីយកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច)

  ១-កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

  ២-ការអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកជាការសង ដែលនាំឱ្យកាតព្វកិច្ចរលត់ ។

- មាត្រា 433 (មូលហេតុនៃការរលត់កាតព្វកិច្ច)

  កាតព្វកិច្ចត្រូវរលត់ដោយហេតុដូចខាងក្រោមនេះ ៖

  ក-ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ព្យាកុលភាព ដូចបានកំណត់ ពីផ្នែកទី ១ (ការសង) ដល់ផ្នែកទី ៥ (ព្យាកុលភាព) នៃជំពូកទី ៧ នេះ ។

# 4. ការអះអាងរបស់ចុងចម្លើយ

តើការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ យ៉ាងណាដែរ ?

A) ដើមចោទនិងចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីបរិភោគ
→ទទួលស្គាល់

B) ការប្រគល់ប្រាក់
→ទទួលស្គាល់

C) ការប្រគល់ប្រាក់នៃB គឺបានធ្វើឡើងដោយផ្អែកលើកិច្ចសន្យានៃA
→ទទួលស្គាល់

D) កាលកំណត់សងបានមកដល់
→អង្គហេតុជាក់ស្តែង

※ចុងចម្លើយទទួលស្គាល់នូវកំណើតនៃសិទ្ធិទាមទារឱ្យសងប្រាក់កម្ចីនោះ។

# 4. ការអះអាងរបស់ចុងចម្លើយ

- ចុងចម្លើយបានទទួលស្គាល់ថា កាតព្វកិច្ចកើតមានឡើងពិតមែន តែបានអះអាងថា កាតព្វកិច្ចនោះបានរលត់ដោយសារការសង។
- ទោះជាមានការទទួលស្គាល់នូវមូលហេតុនៃការទាមទារក៏ដោយ តែការអះអាងដែលអាចបដិសេធសិទ្ធិ គឺជាការ “តវ៉ា”។
- បើសិនជាមានវិវាទ ចុងចម្លើយត្រូវធ្វើការបញ្ជាក់ភស្តុតាង។

# 4. ការអះអាងរបស់ចុងចម្លើយ

- ទោះជាមិនទទួលស្គាល់នូវមូលហេតុនៃការទាមទារក៏ដោយ ក៏គេអាចអះអាងអំពីការតវ៉ាបានដែរ។
  - Ex) "មិនបានខ្ចីប្រាក់ពីដើមចោទទេ តែទោះជាបានខ្ចីក៏ដោយ ក៏បានសងរួចរាល់ហើយដែរ"។
- ប្រភេទនៃការតវ៉ា
  - ការតវ៉ារំលត់សិទ្ធិ : ការសង, អាជ្ញាយុកាល
  - ការតវ៉ាអំពីឧបសគ្គ : ការបង្ហាញឆន្ទៈមិនពិត (មាត្រា353)
  - ការតវ៉ាអំពីការរារាំង : ការតវ៉ាឱ្យអនុវត្តព្រមគ្នា (មាត្រា386)

# 4. ការអះអាងរបស់ចុងចម្លើយ

- តើអ្វីទៅ អង្គហេតុចំបងដែលជាធាតុផ្សំនៃការសង ?

a. ការប្រគល់ប្រាក់
b. A គឺជាការអនុវត្តកាតព្វកិច្ច ដោយផ្អែកលើកិច្ចសន្យា

មាត្រា 384 (ករណីយកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច)

១-កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

២-ការអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកជាការសង ដែលនាំឱ្យកើតពុកិច្ចរលត់ ។

# 4. ការអះអាងរបស់ចុងចម្លើយ

- ការតវ៉ារបស់ចុងចម្លើយ :

“នៅថ្ងៃទី1 ខែមីនា ឆ្នាំ2014 ចុងចម្លើយបានសងប្រាក់ ១ម៉ឺនដុល្លារ ដែលជាការអនុវត្តកាតព្វកិច្ចដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគនៃរឿងក្ដីនេះ ចំពោះដើមចោទ”។

# 4. ការអះអាងរបស់ចុងចម្លើយ

- តើការតវ៉ា និង ការមិនទទួលស្គាល់ ខុសគ្នាយ៉ាងណា ?

ការមិនទទួលស្គាល់ : គឺជាការអះអាងថា មិនទទួលស្គាល់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារទេ ដូច្នេះសិទ្ធិរបស់ដើមចោទក៏មិនកើតមានឡើងដែរ

ការតវ៉ា : គឺជាការអះអាងថា ទោះជាមានការទទួលស្គាល់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារក៏ដោយ តែសិទ្ធិរបស់ដើមចោទត្រូវបានបដិសេធដោយមូលហេតុគតិយុត្តិផ្សេង

- ចុងចម្លើយមានការទទួលខុសត្រូវក្នុងការអះអាងនិងបញ្ជាក់ភស្តុតាង។

※បើសិនជាមិនបានរៀបចំថា តើអង្គហេតុដែលជាមូលហេតុនៃការទាមទារមានអ្វីខ្លះទេ នឹងមានការពិបាកក្នុងការបែងចែកឱ្យបានច្បាស់លាស់អំពីការមិនទទួលស្គាល់ និងការតវ៉ាណាស់។

# 4. ការអះអាងរបស់ចុងចម្លើយ

- តើការតវ៉ា និង ការមិនទទួលស្គាល់ ខុសគ្នាយ៉ាងណា ?

※ត្រូវវិនិច្ឆ័យទៅតាមវិធីចែងក្នុងបញ្ញត្តិច្បាប់ ហើយត្រូវពិចារណាទៅតាមទស្សនៈទទួលខុសត្រូវស្មើភាពគ្នាក្នុងការបញ្ជាក់ភស្តុតាង។

Ex) នៅជប៉ុន ស្តីពីការធ្វើផ្ទុយនឹងគោលការណ៍នៃភាពសុចរិតនិងភាពសច្ចៈ ភាគីម្ខាងទៀតជាអ្នកធ្វើការបញ្ជាក់ភស្តុតាង។

  - មាត្រា 384 (ករណីយកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច)

១-កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

Ex) បើសិនជាមានការអះអាងអំពីការតំណាងដោយគ្មានសិទ្ធិ ចំពោះការទាមទារដោយផ្អែកលើកិច្ចសន្យា ដោយអ្នកតំណាង ដោយសារតែមានការពិបាកក្នុងការបញ្ជាក់ភស្តុតាងថា ពុំមានសិទ្ធិតំណាង ហេតុនេះហើយ ករណីនេះមិនមែនជាការតវ៉ាទេ គឺជាការមិនទទួលស្គាល់។

# 5. ចំណុចវិវាទ

- ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ដើមចោទចំពោះការតវ៉ា

a. ការប្រគល់ប្រាក់

→មិនទទួលស្គាល់

b. a គឺជាការអនុវត្តកាតព្វកិច្ច ដោយផ្អែកលើកិច្ចសន្យា

→មិនទទួលស្គាល់

- a, b គឺជាចំណុចវិវាទ។
- ចុងចម្លើយមានការទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង។

# 5. ចំណុចវិវាទ

- cf) ការតវ៉ាមួយភាគ ៖

  ចុងចម្លើយបានអះអាងថា "ខ្ញុំបានសង4000 ដុល្លារ ដែលជាការអនុវត្តកាតព្វកិច្ចមួយភាគ ចំពោះដើមចោទ" ហើយបើសិនជាការអះអាងនេះត្រូវបានទទួលស្គាល់

  - កាតព្វកិច្ចនឹងរលត់ក្នុងទំហំ 4000ដុល្លារ ដូច្នេះ កាតព្វកិច្ចសងនៅសល់តែ 6000ដុល្លារប៉ុណ្ណោះ។
  - សេចក្តីសម្រេចបញ្ចប់ "ចុងចម្លើយត្រូវបង់ប្រាក់ 6000ដុល្លារ ចំពោះដើមចោទ"។

# ប្តូរដំរ្យាក្រោម

មូលហេតុនៃការទាមទារ

| | |
|---|---|
| A | X・Y បានព្រមព្រៀងនៅ 2013.3.1 អំពីកិច្ចសន្យាឱ្យចងចម្លើយខ្ចីប្រាក់១ម៉ឺនដុល្លារ ដោយឱ្យសងនៅ 2014.3.1 |
| B | X→Y 2013.3.1 បានប្រគល់ ១ម៉ឺនដុល្លារ |
| C | ការប្រគល់ប្រាក់នៃB ដោយផ្អែកលើកិច្ចសន្យានៃ A |
| D | 2014.3.1 បានមកដល់ |

○ ○ ○

ជាក់ស្តែង

ការតវ៉ា (ការសង)

| | |
|---|---|
| a | Y→X 2014.3.1 បានប្រគល់ ១ម៉ឺនដុល្លារ |
| b | a គឺជាការអនុវត្តកាតព្វកិច្ចនៃA |

× ×